BMI0174

# សម្ភាសន៍ជាមួយឈ្មោះ យ មាន ភេទស្រី អាយុ៥៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ

## មុខងារបច្ចុប្បន្នៈ

## សព្វថ្ងៃរស់នៅភូមិប៉ោយព្រីង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## សម្ភាសន៍ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៥៦:១៤

## ២៣ទំព័រ

វណ្ណៈ: អញ្ចឹងថ្ងៃនេះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ហើយខ្ញុំឈ្មោះសុខ វណ្ណៈ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមកនេះមកភូមិឃុំរបស់មីងព្រោះចង់ដឹងរឿងរ៉ាវដែលទាក់ទងនឹងប្រវត្តិអាងត្រពាំងថ្ម ថាតើប្រជាជនយើងទៅលើកនៅអាងត្រពាំងថ្មហ្នឹងមានស្លាប់ដែរអត់ ហើយមានអាហារហូបចុកយ៉ាងម៉េច ហើយគេដាក់កម្រិតវាស់ម៉ែត្រក្នុងមួយថ្ងៃម្នាក់យ៉ាងម៉េចអញ្ចឹង ខ្ញុំចង់ដឹងរឿងរ៉ាវទាំងអស់ហ្នឹង

ហើយជាពិសេសចង់ដឹងពីរបចនាសម្ព័ន្ធកាលដឹកនាំនៅក្នុងតំបន់ហ្នឹង

តំបន់ហ្នឹងគេហៅតំបន់មែនទេ?

មានៈ ចាំ!

វណ្ណៈ: ហើយអញ្ចឹងមានពីណាដឹកនាំខ្លះ ដូចជាប្រធានភូមិភាគ គណៈតំបន់ ដែលមីងស្គាល់មីងប្រាប់ទៅ ហើយបើមីងមិនស្គាល់ទេក៏ហីទៅ?

មានៈ ទេ មិនស្គាល់គេទេ ។

វណ្ណៈ: អញ្ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង តើមីងឈ្មោះអីដែរ?

មានៈ ខ្ញុំឈ្មោះ យ មាន ។

វណ្ណៈ: មីងអាយុប៉ុន្មានហើយ?

មានៈ អាយុ៥៥ ។

វណ្ណៈ: ប្តីរបស់មីងឈ្មោះអីដែរ?

មានៈ ឈ្មោះប៉ុល សឿន ។

វណ្ណៈ: គាត់អាយុប៉ុន្មាន?

មានៈ	អាយុ៥៨ ។

វណ្ណៈ	អញ្ចឹងប្អូនមីងទៀត?

មានៈ	ចា៎!

វណ្ណៈ	សព្វថ្ងៃមីងមានកូនប៉ុន្មាននាក់?

មានៈ	ខ្ញុំមានកូន៦នាក់ ។

វណ្ណៈ	ស្រីប៉ុន្មាន?

មានៈ	ស្រី៤នាក់ ហើយប្រុស២នាក់ ។

វណ្ណៈ	ឪពុកមីងឈ្មោះអីដែរ?

មានៈ	យោ ហាប់ ។

វណ្ណៈ	ចុះម្ដាយ?

មានៈ	ព្រំ ម៉ៃ ។

វណ្ណៈ	ចុះគាត់សព្វថ្ងៃគាត់នៅរស់ទេ?

មានៈ	គាត់ស្លាប់អស់ហើយ គាត់ស្លាប់យូណាស់ហើយ ។

វណ្ណៈ	ស្លាប់សម័យណា?

មានៈ	ស្លាប់ប៉ុន្មានឆ្នាំហើយ ។

វណ្ណៈ	ស្លាប់ក្រោយ៧៩នេះ?

មានៈ	ចា៎!

វណ្ណៈ	ចុះមីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

មានៈ	បងប្អូនខ្ញុំសព្វថ្ងៃនេះមាន៤នាក់ ប្រុស១ ស្រី៣ ។

វណ្ណៈ	អញ្ចឹងទាំងអស់ប៉ុន្មាននាក់?

មានៈ	ទាំងអស់៦នាក់ តែស្លាប់អស់២នាក់ហើយ ។

វណ្ណៈ	អញ្ចឹងសល់៤នាក់?

មានៈ	ចា៎!

វណ្ណៈ	២នាក់ហ្នឹងស្លាប់សម័យណាទៅ?

មានៈ	សម័យនេះដែរ គាត់ស្លាប់រោគគាត់ ។

វណ្ណៈ	ចុះស្រុកកំណើតហ្នឹងនៅណា?

មានៈ	នៅភូមិប៉ោយព្រីង ។

វណ្ណៈ ឃុំ?

មានៈ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ពីដើមខេត្តបាត់ដំបងទេ ឥឡូវខេត្តបន្ទាយមានជ័យ?

មានៈ ចា៎!

វណ្ណៈ ចុះកាលមីងពីដើមឡើយ ពេលដែលមីងធំដឹងក្តីទៅ មីងមានបានរៀនសូត្រទេ?

មានៈ អត់មានបានរៀនទេ ធ្វើតែស្រែ មិនបានរៀនផង ចង់ទៅរៀនខ្ញុំតាមគេទៅម៉ែដេញវ៉ៃ ធ្វើតែ ស្រែ ពេលធំឡើងឃ្វាលតែគោ ។

វណ្ណៈ មីងចង់រៀនដែរ?

មានៈ ចង់រៀនក៏មើលមិនឃើញដែរ?

វណ្ណៈ អត់ទេ កាលពីដើម កាលមីងនៅក្មេងៗ?

មានៈ ចង់ តែម៉ែគាត់មិនឲ្យរៀន គាត់ឲ្យទៅធ្វើតែស្រែ គាត់មិនឲ្យរៀនទេ ។

វណ្ណៈ ចុះមីងចេះភ្ជួរដីដែរ?

មានៈ ភ្ជួររាស់ខ្ញុំចេះ ដាន់ស្រូវអីហ្នឹង ឃ្វាលគោ ប៉ុន្តែរឿងដូចជាសព្វថ្ងៃនេះខ្ញុំមិនចេះភ្ជួរទេគោយន្ត គោអីហ្នឹង ។

វណ្ណៈ ចុះកាលហ្នឹងគាត់ទុកលទ្ធភាពឲ្យកូនប្រុសទៅរៀន?

មានៈ កូនប្រុសមិនបានរៀនទេ ទៅបួសអញ្ចឹងក៏បានរៀននៅវត្ត អត់មានបានឲ្យទៅរៀនទៅសូត្រនៅណាទេ ។

វណ្ណៈ ចុះមីងកាលហ្នឹងពេលរដ្ឋប្រហារឆ្នាំ៧០ ទម្លាក់សម្តេចសីហនុ តើមីងនៅតែភ្ជួរស្រែដដែលឬក៏យ៉ាងម៉េច?

មានៈ ខ្ញុំនៅតែភ្ជួរស្រែនៅគោកយាវ ដល់ពេលសង្គ្រាមមកដល់លន់ នល់ ខ្ញុំមកនៅភូមិគោកលន់ ។

វណ្ណៈ កាលលន់ នល់ អញ្ចឹងទាហានខាងចូលព្រៃម៉ាគីនឹងទាហានលន់ នល់ នៅក្នុងភូមិឃុំនេះមានឡើងមកបាញ់គ្នាទៅមកទេ?

មានៈ បើនិយាយពីរឿងបាញ់ខ្ញុំមិនដឹងទេ ។

វណ្ណៈ មីងអត់ដឹងទេ?

មានៈ ចា៎! វាធំគ្រាន់ដែរ តែខ្ញុំមិនដែលបានដឹង ។

វណ្ណៈ ចុះទម្លាក់គ្រាប់បែកអីមីងដឹងទេ?

មានៈ ទម្លាក់គ្រាប់បែកនៅនេះមាន កាលសម័យលន់ នល់យើងជិតចប់ហើយណា៎ ទម្លាក់ដែរ តែទម្លាក់នៅស្រែះ ខ្ញុំឃើញទម្លាក់នៅស្រែះហ្នឹងឯង អាហ្នឹងជិតចប់ហើយ ។

វណ្ណៈ ចុះដល់ពេលខ្មែរក្រហមចូលមកឆ្នាំ៧៥ហ្នឹង បានមីងចូលកងចល័តតែម្ដងឬក៏យ៉ាងម៉េចដែរ?

មានៈ ខ្ញុំចូលមកហ្នឹងខ្ញុំនៅគោកលន់ ចូលទៅគេមិនឲ្យ ប្រធានភូមិមិនឲ្យខ្ញុំទៅទេ តែខ្ញុំទៅចិត្តខ្ញុំទេ ប្រធានភូមិគាត់ស្រលាញ់ ហើយខ្ញុំក៏រត់ទៅចូលកងចល័ត ។

វណ្ណៈ អញ្ចឹងពេលខ្មែរក្រហមចូលមកឆ្នាំ៧៥ហ្នឹង ក្នុងភូមិនេះគេជម្លៀសចេញទៅក្រៅទៀត ឬក៏អត់ជម្លៀសទេ?

មានៈ គេជម្លៀស ។

វណ្ណៈ គេជម្លៀសទៅខាងណាវិញ?

មានៈ ទៅខាងប៉ោយក្លៀង ។

វណ្ណៈ ប៉ោយក្លៀងចម្ងាយពីនេះប៉ុន្មានម៉ែត្រដែរ?

មានៈ ប្រហែលជា៣គីឡូ ។

វណ្ណៈ ទៅប៉ោយក្លៀងហ្នឹងរយៈពេលប៉ុន្មានដែរបានត្រលប់មកភូមិវិញ?

មានៈ ៣ឆ្នាំហ្នឹង ។

វណ្ណៈ អញ្ចឹងនៅក្នុងសម័យខ្មែរក្រហមអត់មានបាននៅភូមិនេះទេ?

មានៈ អត់ទេ ។

វណ្ណៈ អញ្ចឹងនៅប៉ោយក្លៀង?

មានៈ ចា៎!

វណ្ណៈ អញ្ចឹងនៅប៉ោយក្លៀងដល់ឆ្នាំ៧៩?

មានៈ ចា៎!

វណ្ណៈ ៧៩បានត្រលប់មកនេះវិញ?

មានៈ ដល់យួនចូលបានត្រលប់មកវិញ ។

វណ្ណៈ មីងនៅប៉ោយក្លៀងហ្នឹង តើត្រូវបានមេភូមិមេឃុំអីចាត់តាំងមីងឲ្យធ្វើអីទេ?

មានៈ ខ្ញុំមិនដឹងទេ ខ្ញុំមិនបាននៅភូមិផង ខ្ញុំដើរតែចល័តរហូត ។

វណ្ណៈ ហ្នឹងហើយចល័ត អញ្ចឹងមេភូមិឲ្យទៅចល័ត?

មានៈ ចា៎! ខ្ញុំចល័តរហូត ទាល់តែចប់បានខ្ញុំមកផ្ទះ ។

វណ្ណៈ ទៅចល័តនៅណាខ្លះទៅ?

មានៈ ខ្ញុំចល័តមុនដំបូងនៅអារ៉ាក់បាក់ក ចុះពីអារ៉ាក់បាក់កមកខ្ញុំមកនេះ គេហៅរន្ទះបាញ់ ទេនៅស្អីទេអ៊ំ នៅទួលពុទ្រា នៅទួលពុទ្រានោះមកបានត្រលប់ពីនេះទៅ បានខ្ញុំទៅនៅព្រៃមាន់ត្រលប់ពីព្រៃមាន់ទៅបានទៅត្រពាំងថ្ម ទៅត្រពាំងថ្មហើយនឹងកូនខ្វែង ប៉ុណ្ណឹងឯងអត់មានទៅណាទៀតទេ ត្រលប់ពីកូនខ្វែងមកនៅឈរជើងចូលចល័តតំបន់ ឈរជើងនៅដើមគោទាល់តែចប់បានមកផ្ទះ ។

វណ្ណៈ ឆ្នាំណាមីងចូលចល័តតំបន់?

មានៈ ប្រហែលជាមួយឆ្នាំ មួយឆ្នាំបានខ្ញុំត្រលប់មកចូលព្រៃមាន់ នៅបានមួយឆ្នាំ ។

វណ្ណៈ អាហ្នឹងចូលចល័តតំបន់ហើយមែនទេ?

មានៈ ចា៎!

វណ្ណៈ គេហៅកងចល័តតំបន់?

មានៈ ចា៎!

វណ្ណៈ ៧៦?

មានៈ ចូលតំបន់រហូត នៅរហូតម៉ាចប់ បានយួនចូលមកបានរត់ ។

វណ្ណៈ ចុះមុនដំបូងមីងថានៅណា?

មានៈ មុនដំបូងខ្ញុំនៅគោកលន់ ។

វណ្ណៈ កងចល័តគោកលន់មែន?

មានៈ ចា៎! ហើយអារ៉ាក់បាក់ក ។

វណ្ណៈ គោកលន់ហើយអារ៉ាក់បាក់ក?

មានៈ ហ្នឹងហើយ លើកទំនប់ ជីកប្រឡាយ ។

វណ្ណៈ អញ្ចឹងនៅហ្នឹងលើកទំនប់ ជីកប្រឡាយ?

មានៈ ចា៎! លើកទំនប់ អត់មានធ្វើអីទេ លើកតែទំនប់ ជីកប្រឡាយ ។

វណ្ណៈ លើកទំនប់ ជីកប្រឡាយហ្នឹងដូចថាយើងអត់ទាន់លំបាកទេ ឬក៏លំបាកនូវ ដំបូងថ្មីៗហ្នឹង?

មានៈ អត់ទេ អត់ទាន់អីទេ ។

វណ្ណៈ អញ្ចឹងអត់ទាន់អីទេ?

មានៈ ចា៎! បាយមួយចានស៊ីបបូរ ។

វណ្ណៈ ប៉ុន្តែមានគេស្រាវជ្រាវយកទាហានលន់ នល់ ដឹងថាគេស្រាវជ្រាវយកទាហាន ទាហានលន់ នល់ ដែលទៅសម្លាប់ចោលអីមានទេមីងកាលហ្នឹង?

មានៈ	មាន ដូចពួកខ្ញុំជិត នៅតែរំលងតែស្នែកទេក៏ទៅហ្នឹង គេយកទៅសម្លាប់នៅអារ៉ាក់បាក់ក ។

វណ្ណៈ	ចុះកាលនៅអារ៉ាក់បាក់កហ្នឹង មីងដូចថាពីប្រធានដឹកនាំកាលហ្នឹង?

មានៈ	ខ្ញុំអត់ស្គាល់ទេ គេស្រុកគេផ្សេង ខ្ញុំនៅជាមួយគេ វាឈ្មោះ ភាន់ តែមិនដឹងវាឈ្មោះអី ។

វណ្ណៈ	ឈ្មោះ ភាន់ ហ្នឹងធ្វើអី?

មានៈ	គេធ្វើប្រធានកងធំ ប្រធានវរៈគេ គេដឹកនាំយើង ប៉ុន្តែមិនដឹងថាគេនៅស្រុកណា ព្រោះខ្ញុំមិនបានសួរគេ ព្រោះកាលហ្នឹងយើងអត់មានយកចិត្តទុកដាក់ទេ គេប្រើយើងចេះតែទៅ ។

វណ្ណៈ	អញ្ចឹងគ្នាមីងម៉ាកងចល័តមីងហ្នឹង មានគ្នាប៉ុន្មានរយនាក់ទាំងអស់?

មានៈ	ខ្ញុំគេឲ្យក្តាប់៩០នាក់ ។

វណ្ណៈ	មីងក្តាប់ដែរ?

មានៈ	ចា៎!

វណ្ណៈ	៩០នាក់ហ្នឹងកង៥០ឬក៏រយ?

មានៈ	៩០នាក់នោះ៣កង ម៉ាកង៣០នាក់ៗ គេដាក់យើងប្រធានកងក្តាប់៩០នាក់ បន្ទាប់មកបានម្នាក់៣០ ។

វណ្ណៈ	ចុះម៉ាកងចល័តទាំងអស់ ទាំងអស់ហ្នឹងតើមីងគិតមើល ប្រហែលជាប៉ុន្មានរយនាក់ច្រើនទេ?

មានៈ	មិនដឹងប៉ុន្មានរយទេម៉ាកង ។

វណ្ណៈ	ចុះដូចថាកងមីង មីងកាន់៩០នាក់ ហើយចុះអ្នកផ្សេងទៀតមានកាន់ដូចមីងប៉ុន្មានកងទៅ?

មានៈ	ខ្ញុំនៅអារ៉ាក់បាក់កនោះអត់បានច្រើនទេ តែប៉ុណ្ណឹងឯង ៩០នាក់ហ្នឹងម៉ាវរៈ ។

វណ្ណៈ	ម៉ាវរៈ?

មានៈ	គេឲ្យ៣កងធំ អញ្ចឹងវាម៉ាវរៈ ៣កងធំយើង៩០ៗ៣ដងវាប៉ុន្មានហើយ ។

វណ្ណៈ	វា២៧០នាក់?

មានៈ	ចា៎! វា៣កងម៉ាវរៈ ហើយសុទ្ធតែស្រីៗទាំងអស់ ប្រុសៗអត់មានទេ ។

វណ្ណៈ	អញ្ចឹងមាន៣កង?

មានៈ	ចា៎!

វណ្ណៈ	ចុះអ្នកដែលកាន់ចំនួន២៧០នាក់ហ្នឹងពីណាគេប្រធាន?

មានៈ	ឈ្មោះ ភាន់ ប៉ុន្តែមិនដឹងស្រុកគេនៅណាទេ ព្រោះមិនបានសួរគេ ។

វណ្ណៈ	ចុះកាលមីងកាន់៩០នាក់ហ្នឹង តើមីងដឹកនាំធ្វើអីគេខ្លះទៅ?

មានៈ ដីកតែទំនប់ ដីកប្រឡាយ ។

វណ្ណៈ អញ្ចឹងបាយទឹកអីធម្មតាទេ?

មានៈ បាយទឹកគ្រប់គ្រាន់ ។

វណ្ណៈ ចុះពេលព្រឹកម៉ោងប៉ុន្មានចេញ?

មានៈ ពេលព្រឹកម៉ោង១១បានឡើង ។

វណ្ណៈ ម៉ោងប៉ុន្មានចុះ?

មានៈ ម៉ោង១ចុះ ។

វណ្ណៈ ចុះព្រលឹមឡើង?

មានៈ ព្រលឹមឡើងម៉ោង៧ ។

វណ្ណៈ ចុះម៉ោង៧ ហើយម៉ោង១១ឡើង ម៉ោង១ចុះវិញ ហើយម៉ោងប៉ុន្មានចុះវិញ?

មានៈ ម៉ោង៥ ។

វណ្ណៈ អញ្ចឹងដូចថាម៉ោង៥ហ្នឹងមានធ្វើការយប់ទៀតទេ?

មានៈ អត់មានទេ ថ្ងៃណាប្រជុំក៏ប្រជុំទៅ ហើយថ្ងៃណាអត់ក៏អត់ទៅ មានតែនាំគ្នាដេកហ្នឹងឯងសម្រាកទៅ ។

វណ្ណៈ អញ្ចឹងបន្ទាប់មកទំនប់រនុះបាញ់?

មានៈ មកទំនប់រនុះបាញ់អត់មានបានលើកទេ ទៅនៅហ្នឹងប្រូត ។

វណ្ណៈ ប្រូត?

មានៈ ចាំ! នៅទួលពុទ្រានោះប្រូត អាហ្នឹងខ្ញុំចូលចល័ត តាវ៉ាល់ ហើយ គាត់ហ្នឹងឈ្មោះ តាវ៉ាល់ទៅប្រូត ។

វណ្ណៈ តាវ៉ាល់ ហ្នឹងគាត់អីគេ?

មានៈ តាវ៉ាល់ ហ្នឹងគាត់សង្កាត់..។

វណ្ណៈ តាវ៉ាល់ តាមោង ហ្នឹងគាត់គណៈស្រុកមែន?

មានៈ អត់ទេ គាត់គណៈសង្កាត់ សង្កាត់តាវ៉ាល់ ។

វណ្ណៈ ចុះគណៈតំបន់?

មានៈ គណៈតំបន់ហ្នឹងយូហើយខ្ញុំមិនចាំទេ ។

វណ្ណៈ ចុះមីងនៅកន្លែងរនុះបាញ់ហ្នឹងធ្វើស្រែទេ?

មានៈ ចាំ! ធ្វើស្រែ ។

វណ្ណៈ ធ្វើស្រែហ្នឹងនៅឆ្នាំណា កាលមីងមករន្ទះបាញ់ផ្លាស់ពីនេះវិញហ្នឹង?

មានៈ មិនបានចាំទេ ព្រោះរវល់តែចល័ត មិនដឹងឆ្នាំណាៗទេ យើងមិនបានយកចិត្តទុកដាក់ផង ។

វណ្ណៈ ចុះមីងមកកន្លែងរន្ទះបាញ់ហ្នឹង ប្រហែលជាខែខ្មែរយើងហ្នឹង ខែប្រាំងឬក៏ខែវស្សា?

មានៈ ខែនោះមានខែអី មានតែខែមាឃខែបុស្សហ្នឹង ខែច្រូតយើងហ្នឹងឯង ។

វណ្ណៈ ចុះមីងចេញពីរន្ទះបាញ់ទៅព្រៃមាន់ ហើយទៅព្រៃមាន់ហ្នឹងមីងធ្វើអី?

មានៈ ព្រៃមាន់ហ្នឹងមានតែជីកប្រឡាយ ហើយនឹងលើកទំនប់ដូចតែគ្នាហ្នឹង លើកទំនប់កៀនៗថ្នល់ យើងបណ្ដោយទៅអញ្ចេះ ។

វណ្ណៈ ព្រៃមាន់ហ្នឹងមីងចូលកងចល័តតំបន់ហើយ?

មានៈ អត់ទាន់ទេ ។

វណ្ណៈ អត់ទាន់ទេ?

មានៈ ចា៎! នៅយើងធម្មតាហ្នឹង ។

វណ្ណៈ នៅកងចល័តស្រុក ឬកងចល័តអីអាហ្នឹងនៅព្រៃមាន់ហ្នឹង?

មានៈ មិនដឹងចល័តស្អីគេទេ មិនបានយកចិត្តទុកដាក់ គេថាចល័តៗ គេឲ្យលើកក៏ចេះតែលើកទៅ ។

វណ្ណៈ មីងកាន់តែ៩០នាក់ដដែល អត់មានឡើងទេ?

មានៈ ទៅនោះផ្លាស់ហើយ គេឲ្យខ្ញុំកាន់តែ៣០នាក់ទេម៉ាកង ។

វណ្ណៈ ទៅព្រៃមាន់ហ្នឹងកាន់តែ៣០នាក់ទេ?

មានៈ ចា៎! ក្នុងមួយថ្ងៃគេឲ្យលើក១៥ម៉ែត្រ បើយើងលើកបានពីថ្ងៃទៅ យើងបានសម្រាកពីថ្ងៃ បើយើងលើក..?

វណ្ណៈ ចុះមីង មូលហេតុអីបានជាមីងកាន់៩០នាក់ហើយ គេឲ្យមីងមកកាន់៣០នាក់វិញ?

មានៈ វាខុសគ្នា គេផ្លាស់ខុសគ្នា កាលនោះយើងនៅនេះមុនដំបូងគេឲ្យប៉ុណ្ណោះ ដល់ពេលខ្ញុំមកនេះ ខ្ញុំមិនចេះអក្សរផង គេដាក់ឲ្យយើងប៉ុណ្ណឹង ព្រោះខ្ញុំល្ងង់ ។

វណ្ណៈ លើកទំនប់ហ្នឹង ទំនប់ប៉ុណ្ណាដែរ?

មានៈ ទំនប់មិនធំទេ គ្រាន់តែខ្ពស់ ។

វណ្ណៈ ទំនប់ធ្វើសម្រាប់ធ្វើស្រែ?

មានៈ ចា៎! សម្រាប់ធ្វើស្រែ ធ្វើស្រែប្រាំង ក្នុងមួយថ្ងៃគេឲ្យ១៥ម៉ែត្រឲ្យលើកឲ្យរួច ។

វណ្ណៈ ក្នុងម្នាក់មែន?

មានៈ អត់ទេ ក្នុង៣០នាក់១៥ម៉ែត្រក្នុងមួយថ្ងៃ បើយើងលើករួចម៉ោងប៉ុន្មាន ដូចថាម៉ោង៣-៤-២គេឲ្យឡើងថ្មើរហ្នឹងហើយ គេអត់ឲ្យយើងលើកទៀតទេ គេឲ្យយើងឈប់ ឲ្យយើងសម្រាក ។

វណ្ណៈ ចុះនៅហ្នឹង ភាន់ ហ្នឹងគ្រប់គ្រងដែល?

មានៈ ទេ អត់ទេ ផ្លាស់ហើយ ។

វណ្ណៈ ពីណាគេ?

មានៈ ខ្ញុំមិនបានស្គាល់គេទេ ។

វណ្ណៈ អត់ស្គាល់ទេ?

មានៈ ចាំ!

វណ្ណៈ ចុះនៅព្រៃមាន់ហ្នឹងរយៈពេលយូទេបានទៅដល់ត្រពាំងថ្មហ្នឹង?

មានៈ យូគ្រាន់បើដែរហ្នឹង ជិត២ខែដែរ ។

វណ្ណៈ អ្នក១៧មេសាមានមកធ្វើការជាមួយគ្នានូវ មកហើយប៉ុក៏មិនទាន់មកទេ ពួកភ្នំពេញ?

មានៈ កាលនៅព្រៃមាន់មិនទាន់មកទេ ទាល់តែទៅដល់ត្រពាំងថ្មបានមក ។

វណ្ណៈ អញ្ចឹងនៅព្រៃមាន់ឆ្នាំ៧៥ដដែល?

មានៈ ចាំ! ពួកហ្នឹងមិនទាន់មកដល់ទេ វាដល់ដែរតែវាដល់តិច វាមិនទាន់ចូលខាងភូមិខ្ញុំ ទាល់តែទៅត្រពាំងថ្មបានពួកអ្នកថ្មីមក ទៅទាំងខ្ញុំទាំងគេហ្នឹងឯង ។

វណ្ណៈ អញ្ចឹងដល់ឆ្នាំណាបានមីងទៅត្រពាំងថ្ម? គេចាប់ផ្ដើមពីណាឆ្នាំណាទៅ?

មានៈ មិនដឹងជាឆ្នាំណាទេ ។

វណ្ណៈ ខ្មែរក្រហម មីងចូលកងចល័តបានរយៈពេលមួយឆ្នាំប៉ុក៏ពីរឆ្នាំបានមីងទៅត្រពាំងថ្មហ្នឹង ឧបមា ថា៧៥ខ្មែរក្រហមចូលមក មីងធ្វើ២កន្លែង គោកលន់ ព្រៃមាន់អញ្ចឹងហើយបានប្រហែល ជាមួយឆ្នាំទេបានមីងទៅត្រពាំងថ្មហ្នឹង?

មានៈ ទៅនោះប្រហែលជាបានមួយឆ្នាំ ទៅត្រពាំងថ្មទៅ ត្រពាំងថ្មប្រហែលយូទៅជិតមួយឆ្នាំបានត្រលប់មកនៅគោ ។

វណ្ណៈ ជិតមួយឆ្នាំហ្នឹងចប់ទេ?

មានៈ អត់ចប់ទេ ទាល់តែខ្ញុំមកនៅដើមគោបានមួយឆ្នាំបានចប់ ។

វណ្ណៈ ហេតុអីបានជាអត់ទាន់ចប់អាងត្រពាំងថ្មគេឲ្យមីងទៅធ្វើទំនប់ដើមគោទៀត?

មានៈ គេបិទវគ្គពីនោះមក បានគេឲ្យមកនៅដើមគោ ដើមគោគេឲ្យធ្វើស្រែប្រាំង ទាល់តែចូលចល័ត តំបន់នេះឲ្យធ្វើស្រែប្រាំង ។

វណ្ណៈ ចុះទៅត្រពាំងថ្ម មីងចូលចល័តតំបន់ដែរ?

មានៈ ចូលហើយ ចូលចល័តតំបន់ហើយ លើកទំនប់ ជីកប្រឡាយ ទំនប់គ្រាន់តែបាតក្រោមវា១៥ ហើយកំពស់វា៥ម៉ែត្រ ខ្នងលើ៥ម៉ែត្រ លើកដាក់ឡើង នាមតែលើកតែមិនដែលបានទៅឃើញគេម្ដាក់ម្ដងទេ មិនដែលបានឃើញមែន លើករួចក៏មក ។

វណ្ណៈ ពេលមីងទៅអាងត្រពាំងថ្មហ្នឹង មីងកាន់ប៉ុន្មាននាក់វិញ កាន់៣០នាក់ដែល?

មានៈ កាន់៣០ប៉ុណ្ណោះឯង យើងមិនចេះអក្សរគេមិនឲ្យកាន់ច្រើនទេ ។

វណ្ណៈ ទៅអាងត្រពាំងថ្មហ្នឹង មីងមានដែលបានជួបមីងគឹម រស់ទេ?

មានៈ រស់ ហ្នឹងជួប ។

វណ្ណៈ ហ្នឹងហើយ គាត់កាន់ច្រើនជាងមីង?

មានៈ ចាំ! គេច្រើនជាង គេអ្នកចេះអក្សរ គេចេះៗ តែនៅកងផ្សេងគ្នា ។

វណ្ណៈ អត់មាននៅកងជាមួយមីងទេ?

មានៈ អត់ទេ ។

វណ្ណៈ នៅអាងត្រពាំងថ្មហ្នឹង ទៅដល់ដំបូងគេឲ្យមីងធ្វើអីទៅ?

មានៈ មុនដំបូងគេឲ្យលើកទំនប់ហ្នឹងឯង គេឲ្យលើកប្រឡាយ ។

វណ្ណៈ ចុះមីងថាមានបែងចែកតាមកម្លាំង?

មានៈ ចាំ! បែងចែកតាមកម្លាំង ។

វណ្ណៈ កម្លាំងទី១ប៉ុន្មានម៉ែត្រគីប?

មានៈ កម្លាំងទី១៤ម៉ែត្រគីប កម្លាំងទី២គឺ២ម៉ែត្រគីប កម្លាំងទី៣ ១ម៉ែត្រគីបកន្លះ អ្នក.... ។

វណ្ណៈ អញ្ចឹងមានបែងចែកអញ្ចឹង យើងមើលទៅតាមកម្លាំងទន់ខ្សោយ?

មានៈ ចាំ! យើងមើលទៅតាមកម្លាំង បើហូបបាយទឹកក៏មិនមានជីក ឲ្យគ្នាវែកធ្វើណាបាន ងាប់ក៏ងាប់ហើយ ថាខ្ញុំមិនចង់រំលឹកទេ ខ្ញុំបំភ្លេចចោល ខ្ញុំមិនចង់ចាំទេ ខ្ញុំខឹងខ្ញុំស្អប់ណាស់ ។

វណ្ណៈ ចុះមីងជាប្រធានដឹកនាំក្រុមអញ្ចឹង តើមីងទទួលផែនការដូចសមាជិកដែរ ដូចអ្នកធម្មតាដែរ ឬគ្រាន់តែថាមីងដើរមើលទេ មីងអត់បានវែកបានអីទេ?

មានៈ ខ្ញុំវែកដែរ គេឲ្យវែកដែរ ។

វណ្ណៈ គេដាក់ឲ្យមីងប៉ុន្មាន?

មានៈ	គេដាក់ឲ្យកូនកងរួច អស់ទៅបានគេឲ្យ ខ្ញុំ៤ម៉ែត្រគីប ។

វណ្ណៈ	អញ្ជឹង?

មានៈ	ចា៎!

វណ្ណៈ	មិនមែនថាយើងមើលគេហើយយើងបានរួចខ្លួនទេ?

មានៈ	អត់រួចទេ យើងមិនរួចទេ គេមិនឲ្យយើងរួចទេ មិនឲ្យយើងដើរមើលទេ គេឲ្យយើងលើកទាល់ តែយើងលើករួចគេឲ្យយើងដើរមើលកង កូនក្រុមទៀត គេឲ្យយើងដើរមើល មិនមែនឲ្យ យើងតែលើកទេ បើយើងលើករួចហើយនេះ ខ្ញុំម៉ោង៣លើករួចអញ្ជឹងគេឲ្យដើរមើល ហើយ បើថាកូនកងកូនក្រុមលើកមិនរួចគេឲ្យយើងនៅនោះឯង គេមិនឲ្យយើងឡើងមកទេ ។

វណ្ណៈ	អញ្ជឹងមានតែពិបាកជាងកូនក្រុមទៀត?

មានៈ	ពិបាកមែន ។

វណ្ណៈ	ឲ្យយើងដើរមើលផង ហើយឲ្យយើងរែកផង?

មានៈ	ឲ្យយើងលើក បើយើងលើករួចគេឲ្យយើងធ្វើគំរូ បើយើងលើកមិនរួចក៏ ។

វណ្ណៈ	ចុះកាលទៅលើកអាងត្រពាំងថ្ម មីងមានឃើញ តាវ៉ាល់ ទៅទេ?

មានៈ	កាលហ្នឹងទៅហើយ តាវ៉ាល់ ហើយនឹង តាមោង ។

វណ្ណៈ	ទៅហ្នឹងគាត់ប្រជុំដាក់បញ្ហាអីយ៉ាងម៉េចៗទេ?

មានៈ	គាត់ប្រជុំតែឲ្យលើកទំនប់លើកប្រឡាយ ជីកទំនប់ លើកទំនប់ឲ្យតែរួចហ្នឹង ។

វណ្ណៈ	គាត់មានប្រាប់ថា ឥឡូវទំនប់ហ្នឹងយើងលើកដើម្បីអី យើងធ្វើហ្នឹងធ្វើដើម្បីអីទេ គាត់មាន ដែលនិយាយអញ្ជឹងទេ?

មានៈ	បើនិយាយទៅខ្ញុំដូចជាភ្លេចអស់ហើយ ហើយខ្ញុំឈឺច្រើនផង ខ្ញុំមិនបានយកចិត្តទុកដាក់រឿង ដែលគេមាន ព្រោះតែថាគេឲ្យធ្វើ គេឲ្យលើកឲ្យរួច បង្កបង្កើនផល ។

វណ្ណៈ	អញ្ជឹងមីង ដូចថាកន្លែងលើកទំនប់ហ្នឹង តើមីងបាន់ស្មានមើល ប្រហែលជាប៉ុន្មានស្រុកដែល ទៅលើកនៅហ្នឹង?

មានៈ	ថាមិនត្រូវទេ មនុស្សរាប់ម៉ឺនរាប់សែនណាលោកគ្រូ មិនមែនតែម្នាក់ឯងទេ ច្រើនស្រុក ណាស់ គ្រប់ស្រុកលើកតែត្រពាំងថ្មមួយហ្នឹងឯង សម្រុកតែមួយហ្នឹងឯង តាំងពីស្ពានទី១ដល់ ស្ពានទី២-៣ លើកដល់ដើមប្រើស មើលទៅឡើងប៉ុន្មានគីឡូ៤ជ្រុង

ទាល់តែគេអ្នកបេះបាន គេដឹង ទាល់តែគេកាន់ក្តាប់ គេអ្នកវាស់នោះបានគេដឹង ដូចយើងអាចក់អាចែមមិនដឹងទេ គេឲ្យលើកក៏បេះតែលើកទៅ លើកទាល់តែចប់ ។

វណ្ណៈ: អញ្ចឹងដូចថាពេលលើកហើយ សម្រាកហ្នឹងគេឲ្យយើងញ៉ាំបាយដែរឬក៏យ៉ាងម៉េច ពេលម៉ោង ១១ហ្នឹងឲ្យញ៉ាំបាយវាល់ ឬក៏ឲ្យយើងម៉ាផ្អែត ឬក៏យ៉ាងម៉េច?

មានៈ អត់ទេគេវាល់ ចានយើងតូចដាងហ្នឹងបន្តិច តែម្នាក់មួយចានទេ ។

វណ្ណៈ: បានម្នាក់ចាន?

មានៈ ចា៎!

វណ្ណៈ: ចុះម្ហូបបានអីទៅ?

មានៈ ម្ហូបថ្ងៃណានេះគេស្ងោរ និយាយថាមិនត្រូវទេ ថ្ងៃណានេះក៏បានម្ហូបរាងស្រណោះបន្តិចទៅ ថ្ងៃណានេះក៏អត់ទៅ ស្ងោរទឹកថ្លាឆ្អេង រាវៗហ្នឹងគ្មានរកកម្លាំងម៉េចឃើញ ។

វណ្ណៈ: ចុះមានមនុស្សឈឺស្លាប់អីទេមឹងពេលហ្នឹង?

មានៈ មិនបាច់និយាយទេរឿងឈឺរឿងងាប់ហ្នឹង ងាប់ហ្នឹងវារាល់ថ្ងៃហើយ គ្រុនញាក់ខ្ទួនញ័រ ថ្នាំក៏មិនដែលមានទេ មានតែថ្នាំអាចម៍ទន្សាយ គ្នាលេបណាកើត ដល់ពេលគ្នាគ្រុនញាក់ថាគ្នាហ្នឹងគ្មានសតិអារម្មណ៍ទៀត គ្នាឈឺមែនទែន ទាល់តែគ្នាងាប់ព្រុស វែកៗឡើងងាប់ព្រុស ដួលព្រុសទៅបានសែងទៅពេទ្យទៅ ចោទគ្នាថាគ្នាហ្នឹងសតិអារម្មណ៍ វេទនាខ្លាំងណាស់លោកគ្រូអើយ វេទនាណាស់ មួយថ្ងៃបើខ្ញុំឈប់លើក ដល់ពេលខ្ញុំឈប់គេឲ្យខ្ញុំវែកទឹកក្នុងមួយថ្ងៃឲ្យបាន២ដើងទៀតបានឲ្យឈប់ វាដឹកអត់គ្រប់ទេ វាដាច់ពោះទឹកហ្នឹងខ្លាំងដាង ក្នុងមួយខែលោកក្តួយអើយមិនបានទឹកផ្ងូតទេ និយាយពីចៃចេញអស់ហើយតាមអញ្ចេះៗ សំពត់សជ្រលក់ យកដើមបាក់ក្លឿហើយនឹងដើមគ្រោះជ្រលក់រួចក៏ដាន់ផុក ដានផុករួចរៀងស្រគាំៗទៅក៏បាននាំគ្នាយកទៅបោកទៅបានហាល ហើយស្លៀកទៅ ហើយចៃចេញតាមអញ្ចេះៗចង្កេះអីៗហ្នឹង ហើយអ្នកថ្មីគ្នាអត់មានកម្លាំងមានកំហែងទេ មនុស្សធ្លាប់ស៊ីឆ្ងាញ់ដេកស្រួលណា ដល់ពេលមកធ្វើការរីករ៉ិនទៅអត់រួចទេ គាត់ងាប់មិនមែនធម្មតាទេ រឿងភូមិខ្ញុំដែលថាគេហៅភូមិខ្ញុំនេះ ភូមិស្អីទេ ។

វណ្ណៈ: អញ្ចឹងទឹកក៏អត់បានហូបឆ្អែតម៉ាសេរីដែរ?

មានៈ អត់ទេលោកគ្រូ ។

វណ្ណៈ: បែងចែកគ្នាទៀត?

មានៈ បែងចែកគ្នា សឹងតែថាចែកម្នាក់៣-៤ស្លាបព្រាដឹកណា៎ ទឹកហ្នឹងវាល់ស្លាបព្រាចែកគ្នាណា៎ មិនមែនធម្មតាទេ ខ្ញុំមិនចង់និយាយទេមែនណា៎ មួយថ្ងៃខ្ញុំរែកទឹកបានតែ២ដើងទេ អាបំពង់យើងនេះ ម្នាងបំពង់៥ ម្នាងបំពង់៦ស្រេចតែយើងរែកទេ។

វណ្ណៈ ចុះបើយើងលើកអាងអញ្ចឹង ហេតុអីក៏ខ្វះទឹក?

មានៈ អត់មានទឹកទេលោកគ្រូ ខែប្រាំង កាលនោះទើបតែចាប់ផ្តើមខែប្រាំង អត់ទាន់មានទឹកមានអីទេ។

វណ្ណៈ ហើយចុះដូចថាខាងសង្កាត់ ខាងឃុំ ខាងថ្នាក់ស្រុក ថ្នាក់ខេត្តអីក៏គេអត់ចុះទៅមើលថាអ្នកលើហ្នឹងអត់ទឹក ត្រូវការដឹកទឹកពីខេត្តអីទៅ?

មានៈ ដឹក តែអត់ទាន់ ព្រោះទឹកវាឆ្ងាយ នៅព្រៃជ្រៅអីណា៎។

វណ្ណៈ មានឡានដឹកទឹកទៅទេ?

មានៈ អាត្រាក់ដឹក តែដឹកក្នុងមួយថ្ងៃបានតែ២ដើងទេ ២ដើងហ្នឹងបានយកមកចែក ហើយចែកយ៉ាងម៉េចហ្នឹងសព្វគ្នា គ្នាច្រើនណាស់។

វណ្ណៈ មនុស្សរាប់សែននាក់។

មានៈ ចា៎! មនុស្សច្រើនណាស់ មិនបានសព្វទេ ហើយភូមិខ្ញុំនាំគ្នាទៅសុំតាមអណ្តូងគេ ហើយអណ្តូងមិនមែនជិតទេ បើដើរសឹងតែថាពីនេះទៅស្វាយ ក្នុងមួយថ្ងៃបានតែ២ដើងទេ ២ដើងហ្នឹងយប់បានយកមកឲ្យកូនកងដឹក គ្នាស៊ីបាយរួចក៏នៅចាំឡើងយូ។

វណ្ណៈ អញ្ចឹងអ្នកដែលមិនបានរែកគឺត្រូវរែកទឹកយកមកឲ្យកូនកង ដូចមីងអីហ្នឹងទៅរែកទឹកយកមកឲ្យកូនកង?

មានៈ ដល់ពេលអត់ទឹកខ្លាំងគេឈប់ឲ្យខ្ញុំលើក គេឲ្យខ្ញុំទៅរែកទឹកមកកូនកងដឹក អាហ្នឹងអត់បានលើកគេឲ្យសម្រាក ក្នុងមួយកងគេចាត់ម្នាក់ឲ្យទៅរែកទឹកយកមកដឹក ព្រោះដឹកវាអត់ទាន់។

វណ្ណៈ មីងនិយាយតទៅទៀត ដូចថាហេតុការហ្នឹងចាប់អារម្មណ៍ដែរ ព្រោះថាហេតុអីនៅពេលហ្នឹងគេមិនឲ្យយើង សូម្បីតែអាហារក៏មិនគ្រប់គ្រាន់ សូម្បីតែទឹកក៏មិនឲ្យយើងគ្រប់គ្រាន់ តើគេចង់ ធ្វើអីទៅលើប្រជាជន បើតាមមីងគិតទៅ?

មានៈ មិនដឹងគេគិតធ្វើអីទេ មានតែគេធ្វើអញ្ចឹង គេឲ្យយើងងាប់ គេសម្លាប់ព្រុស១ទៅ ដល់គេធ្វើអញ្ចឹងមិនដឹងគំនិតគេគិតយ៉ាងណា បើយើងមិនដឹងគម្រោងការគេ ចិត្តគេអញ្ចឹង មិនដឹងគេប្រុងធ្វើអីយើង។

វណ្ណៈ ចុះមីង មីងសង្កេតឃើញថាពួក១៧មេសាទៅលើកទំនប់ហ្នឹងដែរ តើពួកហ្នឹងស្លាប់ច្រើនជាង អ្នកមូលដ្ឋានយើងឬក៏ដូចតែគ្នាទេ?

មានៈ អត់ទេ បើគេស៊ីតែបាយម៉េចបានងាប់ ។

វណ្ណៈ អត់ទេ ពួក១៧មេសាដែលជម្លៀសមកពីភ្នំពេញ?

មានៈ អ៎! ពួកអ្នកភ្នំពេញហ្នឹង?

វណ្ណៈ ហ្នឹងហើយ?

មានៈ ងាប់ច្រើនណាស់ ងាប់ដល់ដាច់ពូជ មិនមែនថាលេងទេ ងាប់ឡើងនេះ មើលមីកន្ទួចនេះដាច់ពូជហើយ មើលអត់មានមករកជង ងាប់នៅនេះ ងាប់ឡើងដាច់អស់អាលីងមួយគ្រួសារ អត់មានអ្នកណាមករកខ្មោចរកអីផង ។

វណ្ណៈ ហើយដូចថាមកធ្លាប់នៅស្រួលស្រណុកអញ្ចឹង ដល់ពេលទៅធ្វើការអញ្ចឹងខ្វះទឹក ខ្វះអីសព្វបែបយ៉ាង បាយអីអញ្ចឹងទៅ ហើយយើងមិនសូវចេះធ្វើការទៀតក៏ស្លាប់ទៅ ។ ចុះក្រៅពីស្លាប់ដោយសារអត់អាហារ ក្រៅពីស្លាប់ដោយសារបាក់កម្លាំង ពលកម្មខ្លាំងអីចឹង តើមានស្លាប់នៅក្នុងករណីផ្សេងទៀតដូចថា ថ្នាក់លើគេមើលម៉ោ ដូចថាខាងឈ្លប ខាងឃុំអីគេមើលម៉ោថាម្នាក់ហ្នឹងសកម្មភាពមិនល្អគេចាប់នៅមុខមីងអីមានទេ?

មានៈ ទេខ្ញុំមិនដែលទៅមើលទេ ព្រោះតែគេថាខ្ញុំមិនដែលហ៊ានទៅមើលគេទេ ។

វណ្ណៈ ប៉ុន្តែមានគេចាប់យកទៅវ៉ៃចោលដែល?

មានៈ ចា៎!មាន ប៉ុនគ្រាន់តែខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ ។

វណ្ណៈ តែបើសកម្មភាពអត់បាយ អត់អីនៅតាមហ្នឹងមីងដឹងថាមានជារៀងរាល់ថ្ងៃដែរ?

មានៈ ចា៎!ហ្នឹងឯង កាលណាបើ១ថ្ងៃទៅ២-៣នាក់ កាលណា១ថ្ងៃទៅ៤-១០នាក់ក៏មានដែរក្នុងមួយថ្ងៃ ។

វណ្ណៈ បាទ!ចុះបើមនុស្សរាប់ពាន់នាក់ ។ ចុះនៅក្នុងកងមីង៣០នាក់ហ្នឹង?

មានៈ មិនអីទេ គ្រាន់តែ មេខ្ញុំចេះតែដងទឹកដងអីឲ្យគ្នាគ្រប់គ្រាន់ទៅ ក៏គ្នាចេះតែមានកម្លាំងធ្វើការស្រេចតែមេកង បើមេកងឈ្លាសវៃដងគ្នាបានគ្រប់គ្រាន់ទៅអត់អីទេ គ្រាន់តែគ្នាឈឺបន្តិចបន្តួចទៅ ខ្ញុំស្នើថ្នាំស្នើអីគេបានឲ្យលាបទៅ ខ្ញុំឲ្យសម្រាកទៅកែកុនថា ដូចគ្នាឈឺល្មមៗចេះខ្ញុំឲ្យសម្រាកៗទៅ ។

វណ្ណៈ ចុះបើមីងឲ្យសម្រាក បើថ្នាក់លើគេសួររកមីងដោះស្រាយយ៉ាងម៉េចទៅ?

មានៈ ស្សួររកខ្ញុំដោះស្រាយថា កូនកង់ខ្ញុំឈឺមែន ខ្ញុំប្រាប់គេតាមដំណើរទៅ គេក៏គេមិនថា ប៉ុនគេនៅតែតាមដានយើងអីចឹងហើយ ប៉ុនប៉ះអ្នកខ្លះក៏បេះតែឲ្យលេបថ្នាំរួចបានជាគ្រាន់ទៅក៏ខ្ញុំឲ្យទៅធ្វើការទៅ ធ្វើតែតិចៗក៏ខ្ញុំជួយខ្លះអីខ្លះទៅ រែកទឹកក៏ជួយ មេកងស្រណោះគ្នាក៏ជួយគ្នាខ្លះទៅ ។

វណ្ណៈ: អីចឹងនៅកងមីងមានអ្នកថ្មីទេ អ្នក១៧មេសាមកពីភ្នំពេញ?

មានៈ ចា៎!អ្នកថ្មីមានកំប៉េះ(ច្រើន) ប៉ុនកំប៉េះមិនអីទេខ្ញុំបេះតែជួយផ្តល់វាទៅ ស្រណោះគ្នាក៏ឲ្យសម្រាក២-៣ ថ្ងៃទៅក៏ឲ្យសម្រាក១ម្តង ៤-១០ថ្ងៃក៏ឲ្យសម្រាកម្តង ។ បេះតែមើលទៅវាយ៉ាប់យឺន ខ្លាំងក៏ខ្ញុំឲ្យសម្រាកពួកអ្នកភ្នំពេញ ប៉ុនខ្ញុំភ្លេចឈ្មោះវាអស់ហើយទៅអស់ហើយ ។ កាលដែលនៅជាមួយគ្នា គេថាបើខ្ញុំបានទៅវិញខ្ញុំមិនបានភ្លេចទេដល់គេទៅគេភ្លេច ខ្ញុំមិន ដែលស្គាល់ទេ គេទៅឆ្ងាយៗទៅគ្នាមិនដែលបានទៅមករកគ្នាក៏មិនដែលបានស្គាល់គ្នាទៅ ។ មកដល់សព្វថ្ងៃឡើងប៉ុន្មានឆ្នាំមកហើយ ។

វណ្ណៈ: ជួនកាលមីងមកនេះវិញគេមិនបានដឹងថា មីងនៅបោ៉យក្លឿងអីចឹងទៅក៏ដាច់ គេមិនបានដឹងថារកមីងនៅកន្លែងណា?

មានៈ ចា៎!ហ្នឹងឯង ប៉ុននៅតែក្នុងចល័តត្រពាំងថ្ម ចុះពីត្រពាំងថ្មមកក៏គេមកនៅដើមគរ ក៏បែកគ្នាដល់តែពេលយួនចូលមកបែកគ្នានៅរៀងខ្លួន មកផ្ទះរៀងខ្លួន មកដើមគរគ្មានអីទេស្រួល ។

វណ្ណៈ: បាទ!អីចឹងខ្ញុំចង់សួរបញ្ជាក់ទៅអាងត្រពាំងថ្មទៀត កាលហ្នឹងមីង អាងត្រពាំងថ្មហ្នឹងកាលហ្នឹង យាយបែម អីមកដល់ឬនៅមិនទាន់ដល់ទេ នៅអាងត្រពាំងថ្មហ្នឹង?

មានៈ ទេ!យាយបែម ហ្នឹងមិនទាន់មកដល់ទេ ។

ជិតខាង: មកហើយ ។

មាន : អ៊ូ!មកហើយ ។ ប៉ុន្តែមកមិនទៅខាងខ្ញុំទេ ខ្ញុំមិនបានដឹងទេ ។

វណ្ណៈ: ចុះមេការមីងនៅត្រពាំងថ្មហ្នឹង?

មានៈ ត្រពាំងថ្ម ប៉ុនគេទៅមែនប៉ុន្តែគេមិននៅតែមួយកន្លែងទេ នៅខ្លាំងជុំគេនៅស្ពានទី១ ។ ស្ពានទី១យើងជិតពីងពួយ គេនៅតែហ្នឹងឯង គេបោះជុំនៅតែហ្នឹងឯងគេទៅនោះគេទៅម្តងៗទេ គេចុះទៅក្រុមខ្ញុំអាទី២ ទី៣នោះមិនសូវបានចុះទៅទេ ។

វណ្ណៈ: បាទ! មីងនៅអាងត្រពាំងថ្មហ្នឹង ខ្ញុំចង់សួរដូចថា ពេលដែលថាដាក់កំណត់៣ម៉ែត្រគីបបើមិនហើយ យើងត្រូវធ្វើយ៉ាងម៉េច?

មាន៖ បើមិនហើយគេឲ្យលើកទាល់តែហើយ ។

វណ្ណៈ ដើម្បីស្នែកទទួលផែនការណ៍ថ្មីទៀត?

មាន៖ គេវាស់ដីឲ្យរបស់ខ្ញុំ៤ អាអ្នក៣នោះបើមិនហើយគេអត់ឲ្យឡើងទេ គេឲ្យនៅយកបាយយកអីទៅហូបនៅ ឡើងពីហូបបាយហ្នឹងគេឲ្យទៅលើកវិញ គេឲ្យយើងដេកនៅក្នុងអន្លង់ហ្នឹងឯងឲ្យនៅក្នុងអន្លង់ហ្នឹងគេមិនឲ្យយើងឡើងនោះទេ ។ បើយើងលើករួចបានៗឡើង បើយើងលើកមិនរួចគេមិនឲ្យយើងឡើងទេ គេឲ្យយើងនៅអន្លង់ហ្នឹង ខ្ញុំសព្វថ្ងៃបាក់ដល់សព្វថ្ងៃឈឺ៤ឆ្នាំហើយខ្ញុំគ្រាន់តែឈឺ ទៅណាមិនរួចទេ លេបថ្នាំរាល់ថ្ងៃ បើមិនបានថ្នាំលេប ១០ថ្ងៃដឹងតែ៣រយៗរាល់ថ្ងៃ ។ កូនរកឡើង អ្នករកប្ដីដងអីដងឡើងរកឡើងគេធុញអស់ហើយ ។

វណ្ណៈ មីងឈឺដោយសារអី ដោយសារបាក់កម្លាំងឬក៏យ៉ាងម៉េច?

មាន៖ ចាំ! ដោយសារបាក់ហ្នឹងឯង គេថាខ្ញុំហ្នឹងឈឺបាក់ ដែលធ្វើការធ្ងន់ពេកក៏ឈឺបាក់ ។ រោគមាន ច្រើនមុខណាស់ខ្ញុំ រោគក្រពះពោះវៀន កាលនោះខ្ញុំប្រសែប្រសាទក្បៀតឈាមខ្សោយ ឈាមខ្ញុំបានកាលណា៩ កាលណា៧ កាលណា៦កន្លះ បៀតតែនឹងទៅដែរ ។

វណ្ណៈ បាទ!អីចឹងដូចថាកន្លែង បងប្អូនយើងលើកអីចឹងតើយើង មានធ្វើរោងធ្វើអីត្រឹមត្រូវមានគ្រែដេកទេត្រឹមត្រូវដែរឬអត់?

មាន៖ ចាំ!គ្មានគ្រែទេ គ្រាន់តែរោងហ្នឹងឯង រោងបាំងសំពត់កៅស៊ូ ធ្វើរោងខ្លួនឯង ធ្វើម៉ាកងៗ គ្នាអត់បាំងកៅស៊ូក៏នាំគ្នាក្រាលសំពត់កៅស៊ូ ចង់មុងដេកទល់នឹងដី មិនដែលមានគ្រែ មានស្អីទេ នាំគ្នាដេកតែនឹងដី ប៉ះណាក៏ក្រាលកៅស៊ូភ្លៀងព្រាកៗទៅក៏គ្របកៅស៊ូពីលើទៅ បើថាមិនជិតនាំគ្នាដេកត្រាំទឹកត្រាំភក់ ។

វណ្ណៈ អីចឹងដូចមីងគ្រប់គ្រងគ្នា៣០នាក់ហ្នឹង តើមានប្រធានណាគេមកស្ដីឲ្យមីងតទៀតទេ?

មាន៖ ទេ!មិនដែលថាមានកសាងខ្ញុំទេ មានតែខ្ញុំម៉ាបដិវត្តន៍រហូតមិនដែលមានអ្នកណាមកកសាងខ្ញុំទេអត់ដែលមានទេ ។ គ្រាន់តែគេថាខ្ញុំ រៀននេះ តាមរូបរាងនេះ ថាខ្ញុំរៀនថ្នាក់ទីបញ្ចប់ បើកូនកុងសីធ្វើការនឿយហត់ ម្ល៉េះហើយនៅតែខ្ញុំស្អាតទៀត គេថាខ្ញុំ គេនឹងយកខ្ញុំទៅវៃចោលលោកគ្រូមែនណាំ! គេចាប់ចងខ្ញុំចេះហើយ ដល់ខ្ញុំបានមីងខ្ញុំមីងរី មីងបូនេះគាត់សព្វថ្ងៃគាត់បានប្ដីទៅនៅជប់ហើយ ។ ហើយគាត់ថា បើសិនជាគាត់មិនចេះអក្សរគាត់ឲ្យខ្ញុំដើរតាមគាត់៥ថ្ងៃ កន្លះខែគេឲ្យខ្ញុំដើរតាមកន្លះខែក្នុងម៉ាភូមិឲ្យធ្វើការ៣ថ្ងៃៗ ៣ថ្ងៃគេឲ្យខ្ញុំសរសេរដូចលោកគ្រូអីចឹងឯងសរសេរ កត់របាយការណ៍ឡើងទៅគេ ប៉ុន្ដែខ្ញុំអត់ចេះសោះ ខ្ញុំ

មិនចេះទាល់តែសោះអក្សរខ្ញុំមិនចេះផង ដល់គេតាមដានថាកូនអ្នកក្រមែន ពីដើមមកកូនអ្នកកសិករទេ ធ្វើតែស្រែគ្នាក្នុរតែស្រែ ប៉ុន្តែម៉ែឪគ្នាស្អាត ។

វណ្ណៈ ចុះហេតុអីគេនៅភូមិហ្នឹងអត់ដឹង អាហ្នឹងពួកនិរតីចូលម៉ោ?

មានៈ ចាំ!ពួកគេនិរតីហ្នឹងហើយ គេចូលមក ។

វណ្ណៈ គេចូលមកគេចាប់តាម៉ោន តាក្រុក តាវ៉ាល់អីយកទៅវៃចោលអស់ហើយពេលហ្នឹង?

មានៈ ចាំ! ភាគគីនិរតីនោះហើយគេយកអស់ហើយ ហើយគេថាខ្ញុំកូនកុងសី ។

វណ្ណៈ ដល់ពេលហើយមីង គេចោទថាមីងកូនកុងសីទៀត?

មានៈ ចាំ!គេថាបើរៀនថ្នាក់ទីបញ្ចប់ បើសិនកូនៗកុងសី ។ ការពិតខ្ញុំមិនដឹងអីទេ នៅតែស្រែសោះ ។

វណ្ណៈ ចុះពេលនិរតីចូលម៉ោឆ្នាំណាមីងដឹង?

មានៈ មិនដឹងទេ ។

វណ្ណៈ ជិតចប់វៀតណាមចូល ។

មានៈ ជិតចប់ហើយៗ យើងចូលខែ យើងថា៧-៨ខែចុះចប់ ពួកវាចូលមក ។ ហ្នឹងខ្ញុំមកខាងដើមគរហើយ ។

វណ្ណៈ អិចឹងនិរតីចូលមកគេចាប់តាវ៉ាល់អីដែរ?

មានៈ ចាំ!គេចាប់ហើយភាគីពួកយាយស្ដីនេះ ។

វណ្ណៈ យាយថែម?

មានៈ ចាំ!ហ្នឹងឯងយាយថែម នោះឯងប្រធានធំ ។

វណ្ណៈ យាយថែម គាត់ធ្វើអីយាយថែម?

មានៈ គាត់ធ្វើខាងស្ដីៗគេទេ ព្រោះតែគេថាប្រធានធំៗ ។

វណ្ណៈ អីចឹងពេលដែលនិរតីចូលមកគេចាប់ចងមីងដែរ?

មានៈ ទេ!ពេលដែលយូរមក ចូលមកជិតបាន៣-៨ខែនោះ បានគេចោទខ្ញុំថាខ្ញុំកូនកុងសី គេចាប់ ។

វណ្ណៈ ពីណាគេអ្នកចាប់?

មានៈ ខាងនោះឯង ខាងនិរតី ។

វណ្ណៈ ពួកនិរតីចាប់?

មានៈ មីកាយ៉ន ។

វណ្ណៈ ចាប់មីងឆ្នាំណា?

មានៈ　មិនដឹងឆ្នាំណាទេ ជិតចប់ទៅហើយ ។

វណ្ណៈ　៧៨ហ្នឹង?

មានៈ　ចា៎!ប៉ុនហ្នឹងឯង ជិតចប់ហើយ ។

វណ្ណៈ　ចាប់ដំបូងយ៉ាងម៉េចដែរ ចងមីងដែរ?

មានៈ　គេចោទខ្ញុំរួច គេចោទក្រោយនេះគេថាខ្ញុំនេះខុសសីលធម៌ជាមួយបង យឿត នៅភូមិព្រីងការ ពិតខ្ញុំមិនដឹងអីផង ។

វណ្ណៈ　ចុះម៉េចបានរួចវិញ?

មានៈ　ឆ្លើយ ខាងប្រុសឆ្លើយថា គាត់មិនបាននិយាយជាមួយខ្ញុំទេ គាត់គ្រាន់តែស្រឡាញ់ទុកក្នុងចិត្តគាត់ អាប្រុសនោះប្រធានវរៈកងធំ អុំះ!ណែ៎អនុប្រធានគាត់ហ្នឹង ។ កាលហ្នឹងបានគាត់មីងទៅ បានរួចខ្លួន ប៉ុន្តែគេនៅតាមដានយើងតែចឹង ។

វណ្ណៈ　បាទ!ប្រុសនោះឈ្មោះអី ប្រុស?

មានៈ　ឈ្មោះបង យឿត ។ បងយឿត សព្វថ្ងៃគាត់អត់នៅនេះទេ គាត់ទៅសហរដ្ឋហើយ ។

វណ្ណៈ　បាទ!បងយឿត ហ្នឹងគាត់ប្រធានដែរកាលហ្នឹង?

មានៈ　អនុប្រធានខាងប្រុស១ ។

វណ្ណៈ　ប្រធានវរៈ?

មានៈ　ចា៎!អនុប្រធានវរៈ ហើយប្រធាននោះឈ្មោះបងសារឿន នៅស្រុកអីគេ ស្រុកនៅខាងទឹកជោរ បងសារឿន នៅខាងទឹកជោរ ។

វណ្ណៈ　អីចឹងបង យឿត ហ្នឹងគាត់ប្រកែកថាមីងមិនបាននិយាយអីជាមួយទេ?

មានៈ　ចា៎!គាត់ស្រឡាញ់ទុកក្នុងចិត្តទេ ហើយត្រង់ដែលគាត់នឹងខ្ញុំនិយាយផ្ទាល់មាត់គ្នានេះ មិនបានដឹងអីទេ ។ គាត់ឆ្លើយអីចឹងទៅបានរួចខ្លួន គេកសាងយើង ។

វណ្ណៈ　ចុះអ្នកមកចោទមីងហ្នឹង មីងស្គាល់ឈ្មោះអី?

មានៈ　ដែលចោទនោះឈ្មោះអីទេ វាក្មេចឈ្មោះស់ទៅហើយ លោកគ្រូអើយវាយូរទៅហើយ ខ្ញុំមិនបានទៅចាត់ទុកនិរតី ប៉ុនខ្ញុំស្គាល់តែឈ្មោះបងយ៉ន មួយប៉ុនបងយ៉ន ហ្នឹងគាត់ចិត្តល្អគាត់ជួយខ្ញុំដែរ និរតីដែរប៉ុន្តែគាត់ចិត្តល្អ ។

វណ្ណៈ　ចុះគេថានៅហ្នឹងដៃដល់ឈ្មោះ សាត ឈ្មោះខុម ឈ្មោះហឿនឈ្មោះអីនោះមីងស្គាលទេ? ស្រី១ទេ តែមកពីនិរតី ថាចាប់មនុស្សសាហាវដែរ?

មានៈ　អ៊ូ!សាហាវមនុស្សច្រើនដែរ តែវាក្មេចឈ្មោះអស់ទៅហើយ ។ ឈ្មោះ យាយ ម៉ន ។

វណ្ណៈៈ គាត់ចាស់បានហៅយាយ ម៉ន?

មានៈ ទេ!មិនចាស់ទេ គាត់ក្មេងៗមិនចាស់ទេ ។

វណ្ណៈៈ មានដឹងថាយាយម៉ន នៅណារាល់ថ្ងៃ?

មានៈ ទេ!គេនាំគ្នាឡើងទៅបេះហើយ ប៉ុនមិនដឹងថាទៅនៅខាងណាទេ ។ ពេលយួន ចូលមកគេនាំគ្នាដឹកទៅម៉ាអាត្រាក់ទៅបេះ ។

វណ្ណៈៈ អីចឹងឈ្មោះម៉ន ស្រី?

មានៈ ស្រី ។

វណ្ណៈៈ គាត់កាចយ៉ាងម៉េចទៅ គាត់ដែលចាប់មនុស្ស គាត់ដែលសម្លាប់មនុស្សទេ?

មានៈ ទេ! គាត់កាចដូចជាថាយើងខុសអីតិចតួចទៅ ក៏គេប្រុងចាប់យើងយកទៅវៃចោលទៅ ប៉ុន្តែគេអ្នកល្អមួយចំនួនទៅ គេបេះតែជួយៗសម្រួលទៅដូចថា គ្នាខុសបន្តិចបន្តួចក៏កសាងម្តង ១ដង ២ដង ៣ដង ។ ដល់៣ដងគេកសាងយើងមិនបាន គេយកយើងទៅវៃចោល ។

វណ្ណៈៈ បាទ!អីចឹងខាងនិរតីមកហ្នឹងក៏មានអ្នកល្អដែរ?

មានៈ ចា៎! មានអ្នកល្អ មិនមានតែអ្នកអាក្រក់ទាំងអស់ទេ អ្នកល្អដែលនៅជាមួយខ្ញុំដើមគរនោះល្អម្នាក់ដែលគាត់ជួយខ្ញុំ ។

វណ្ណៈៈ បាទ! អីចឹងដូចថា កាលជំនាន់ហ្នឹងជំនាន់តាក្រក ហើយនឹងជំនាន់យាយចែម ចូលមកហ្នឹងតើការផ្លាស់ប្តូរនៃការសម្លាប់ ឬក៏ខាងនិរតីចូលមកស្លាប់កាន់តែច្រើន ឬក៏ជំនាន់តាក្រក ស្លាប់ច្រើនឬយ៉ាងម៉េចមីងបើតាមមីងគិត?

មានៈ ដែលស្លាប់ច្រើននោះខ្ញុំមិនសូវជាដឹងទេ ។

ជិតខាងៈ ខាងនិរតីហ្នឹងឯង ។

មានៈ ម៉ាជំនាន់និរតីហ្នឹង ប៉ុន្តែខ្ញុំដឹងតែកាលខ្ញុំនៅចល័តនោះ ដល់ពេលគេចូលមកតាមភូមិគេសម្លាប់ច្រើន ខ្ញុំមិនដែលបាននៅតាមភូមិផង មិនដឹងទេ ដល់សួរគាត់នៅតាមភូមិបានដឹង ។ ដល់សួរអ្នកនៅតាមភូមិហ្នឹងឯង ខ្ញុំនៅចល័តនារីតែរហូតបាត់អីទេកន្លែងខ្ញុំ មានតែកន្លែងគេផ្សេងៗ ។

វណ្ណៈៈ បាទ! អីចឹងអ្នកតាមភូមិ គ្រោះថ្នាក់ច្រើនជាងអ្នកនៅចល័ត?

មានៈ ចា៎!អ្នកតាមភូមិគ្រោះថ្នាក់ច្រើនជាងអ្នកនៅចល័តឆ្ងាយណាស់ ។

វណ្ណៈៈ បាទ!ម៉េចបានអ្នកតាមភូមិគ្រោះថ្នាក់ច្រើនជាងមីង?

មានៈ មិនដឹងជាម៉េចដែរ ដល់តែសួរគាត់ចាស់ៗដែលនៅតាមភូមិបានដឹង ។ មកសួរខ្ញុំនៅចល័តអត់អីទេ ។

វណ្ណៈ អ៊ីចឹងពេលដែលកងចល័តមីងឈប់ធ្វើនៅអាងត្រពាំងថ្មហ្នឹង មីងចេញពីអាងត្រពាំងថ្មមកគំនប់ ដើមគរ៣ដើម កាលហ្នឹងគេនៅលើកបន្តទៀតអត់ទាន់ហើយទេ?

មានៈ ទេ!លើកហើយៗ ចប់វគ្គហើយគេបិទវគ្គហើយ ។

វណ្ណៈ អ៊ីចឹងចប់ហើយ?

មានៈ ចប់ហើយគេលេងសិល្បៈឲ្យមើលរួច គេលេងឲ្យមើលរួច គេឲ្យចេញមក ។

វណ្ណៈ ចុះគេថាមាន ឆោម ឆវិន ច្រៀងដែរកាលហ្នឹងមែនទេ?

មានៈ ច្រៀងហ្នឹងវាមានគ្រប់កន្លែងហ្នឹង ដូចខ្ញុំថាម៉ាត្រពាំងថ្មហ្នឹង មួយកន្លែងទៅ ម៉ាកន្លែងពួកខ្ញុំនេះម៉ាកន្លែងទៅ កន្លែងនៅគេទី១ នោះគេម៉ាកន្លែងគេម៉ារោងទៅ ។

វណ្ណៈ អ៊ីចឹងពេលទំនប់លើកហើយទាំងអស់គេមានជប់លៀងដែរអ៊ីចឹង?

មានៈ ចា៎!គេជប់លៀង ។

វណ្ណៈ ជប់លៀងគេឲ្យយើងញាំុយើងឆ្អែតដែរ?

មានៈ ញាំុឆ្អែត ម៉ាពេលហ្នឹងហើយ ម៉ាពេលមួយថ្ងៃហ្នឹង ។

វណ្ណៈ មានកាប់គោ កាប់សាច់ជ្រូកអីដែរ?

មានៈ ចា៎! ជ្រូក គោគេ គេកាប់ឲ្យស៊ីបរបូរណ៍ គេលេងសិល្បៈយប់ឡើងគេដាក់សិល្បៈឲ្យមើល ។

វណ្ណៈ បាទ!ឆ្នាំណាគេចប់បិទវគ្គហ្នឹង មីងចាំខែឆ្នាំទេ?

មានៈ មិនចាំទេ! មិនបានចាំទេគេចប់បិទវគ្គហ្នឹង ។

វណ្ណៈ បើខែខ្មែរយើងលើកហើយហ្នឹងនៅខែវស្សាឬខែប្រាំង?

មានៈ ខែវស្សាហ្នឹងឯង ខែយើងខែពិសាខនេះ ក៏ចប់ហើយឃើញផ្គរមក ពិសាខជេស្ឋយើងនេះឯង បើខែខ្មែរយើង ។

វណ្ណៈ អ៊ីចឹងកាលចាប់ផ្ដើមប្រាំង ចាប់ផ្ដើមលើក?

មានៈ ចា៎!ខែចែត្រ ខែផល្គុនចែត្រយើងនេះឯង ដល់ពិសាខបានរួច បាន២-៣ខែៗបានរួច ។ មនុស្សសម្រុកឡើង ។

វណ្ណៈ បាទ!អ៊ីចឹងចុះពីហ្នឹងមក ហើយមីងមកដើមគរ៣ដើមហ្នឹងអាហ្នឹងលើកទំនប់មួយដែរ?

មានៈ ចា៎!អាហ្នឹងអត់លើកទេ ហ្នឹងធ្វើស្រែប្រាំង ។

វណ្ណៈ អ៊ីចឹងកន្លែងហ្នឹងគេថាមានទំនប់មួយដែរ?

មានៈ ទំនប់ហ្នឹងដីរបស់គេលើកទេ ដីរបស់ខ្ញុំមិនបានលើកផង ។

វណ្ណៈ    អីចឹងមានអ្នកលើកផ្សេង មានអ្នកធ្វើស្រែប្រាំងផ្សេង?

មានៈ    ចា៎! គេលើករួចទៅបាន ពួកខ្ញុំមកនាំគ្នាធ្វើស្រែប្រាំងបណ្ដោយ ។ នាំគ្នាទៅភ្ជួរធ្វើស្រែប្រាំង ដកក្នុងមួយឆ្នាំ២ដង ។ ដល់ធ្វើក្រោយទៀតម្ដងក្រោយទៀត កំពុងតែប្រូតកំពុងតែបានស្រូវ មករហាចរហើយ្លួនចូលមកក៏ចប់បណ្ដោយ ។ ធ្វើបានតែម្ដងទេ ម្ដងបេះស្រូវហ្នឹងមិនដឹងគេយក ទៅណាអស់ទេ ស្រូវកំបេះកំពាយស្រូវ(ស្រូវច្រើន) ។

វណ្ណៈ    ស្រូវច្រើន?

មានៈ    ចា៎!ច្រើន ។

វណ្ណៈ    តែម៉េចយើងនៅតែខ្វះខាតអីចឹងបើស្រូវច្រើន?

មានៈ    ប៉ុនអត់ខ្វះខាតទេ ឲ្យហូបម៉ាចានៗម៉ាវែ្ឆតៗ ប៉ុនវាខ្វះរឿងម្ហូប ម្ហូបមិនសូវមានបរបូរណ៍ទេ បើរឿងបាយវាបរបូរណ៍ ព្រោះខ្ញុំចល័តណាស់ មិនដែលអត់ទេ ។

វណ្ណៈ    ចុះបើយើងហូបបរបូរណ៍ ចុះហេតុអីអ្នកភូមិអ្នកស្រុកអីស្លាប់ច្រើនម៉្លេះ?

មានៈ    ទេ!តែអ្នកស្រុកទេអត់បរបូរណ៍ អារឿងស្រុកនេះស្រេចហើយ ។ បើរបស់ខ្ញុំដែលចូលចល័ត តំបន់វិញគឺបរបូរណ៍ហើយកន្លែងខ្ញុំនោះ កន្លែងដើមគ ។ គ្មានអត់ គ្មានឃ្លានទេ កន្លែងដើមគរ ៣ដើម                    អាអូននិយាយឲ្យខាងកន្លែងគេខ្ញុំមិនដឹងទេ បើនៅកន្លែងខ្ញុំគរ៣ដើមដឹងតែស្រួលហើយ    បងប្អូនទៅប៉ុន្មាននាក់ក៏បានបាយហូបឆ្អែតដែរ មិនដែលឲ្យអត់ទេ ។

វណ្ណៈ    ចុះអ្នកតាមភូមិហូបមិនឆ្អែតវិញ?

មានៈ    តាមភូមិបបរមួយវែក អ៊ុះ!៣វែក សិត(ប្រមូល)ទៅបានប៉ុននេះម៉ាស្លាបព្រាទេ ។ ខ្ញុំមក លេងម៉ែខ្ញុំ ម៉ែខ្ញុំធំតែក្បាលជង្គង់មកលេងម្ដងៗ ខ្ញុំមិនចង់មកលេងទេ ។ បងថ្លៃខ្ញុំធំតែក្បាល ជង្គង់ឡើងធំជាងខ្លួនទៀត ។ បបរមួយខ្ទះមកគេថា បងយ៉ន ឲ្យខ្ញុំយកសំបុត្រមកឲ្យសង្កាត់ ក្នុង សង្កាត់យើងថានឹងដកទៅ ឈ្មោះ ខា ខ្ញុំយកសំបុត្រមកឲ្យគេមែន សំបុត្រគេមិនដឹងម៉េចទេ ប៉ុនគេប្រើខ្ញុំមក ខ្ញុំមកក៏ខ្ញុំឃុំមុខឡើងជិត ខ្ញុំកូរអាបបរនោះហើយ គេហៅឈ្លបៗពីជ៉ាយ ក្លៀងមកចាប់ខ្ញុំ គេថាខ្ញុំនារីស៊ើបការ ។ ដល់មកដល់គាត់ក៏ឃើញខ្ញុំទៅ នារីនៅនេះទេ ម៉ែឲ្យវា នៅនេះហើយ ចល័តទេ ។

វណ្ណៈ    បាទ!អីចឹងអ្នកតាមភូមិក្បាលជង្គង់ធំជាងខ្លួនទៅទៀត?

មានៈ    ចា៎! អួយធំមែន បើអង្គុយបេះ នេះហើយក្បាលជង្គង់ ផុតក្បាលទៅបេះ មិនធម្មតាទេ ខ្ញុំមិន ចង់មកឃើញម៉ែឪខ្ញុំទេ ។ ចុះបើបបរ៣វែក អា៣វែកយើងត្រឡោកប៉ុននេះ ដាក់៣

គរបេះទៅ ដាក់៣វែកសិតមកប៉ុននេះឯង១ក្នុង១នាក់ ។ ម៉ែខ្ញុំផងគាត់យកអាទឹកបបរនោះដាក់លាយ ដូចយើងបេះស្លឹកឈើ ស្លឹកបាស់ ស្លឹងអី បានក៏ដាក់លាយប្រទាលអី ដាក់លាយទៅនឹងទឹកបបរទៅ អាកូនប៉ុននោះឲ្យចៅៗ ។ បងខ្ញុំបងស្រីខ្ញុំអ៊ំ ម៉ុន នោះ ទិតម៉ាប់នោះបានមកដល់សព្វថ្ងៃ បានប្រពន្ធពីនោះឈឺហើយ ។ បានប៉ុននេះទេឲ្យចៅ ក៏ផុតពីនេះដាក់បន្លែដាក់បន្ការទៅក៏នាំប្ដីហូបទៅ កូនៗចេញចល័តអស់ហើយគ្មានអ្នកណានៅទេ ។

វណ្ណៈ: អីចឹងមានន័យថា នៅក្នុងភូមិហ្នឹងស្លាប់ច្រើនដាងនៅកងចល័តទៀត?

មានៈ: ច្រើនណាស់ តាមភូមិនោះ ងាប់ដោយឈឺក៏ងាប់ច្រើន ងាប់គេវ៉ៃក៏វ៉ៃច្រើន ប៉ុនខ្ញុំមិនសូវដឹងទេ សួរគាត់ចាស់ៗ បើខ្ញុំនៅចល័តរហូតខ្ញុំមិនដែលមកផ្ទះផង ដល់ចប់យួនចូលបានខ្ញុំមកផ្ទះ ។

វណ្ណៈ: ចុះនៅតំបន់៥ហ្នឹងមីងដឹងថា នៅកន្លែងណាមានគុកសន្តិសុខសម្រាប់ដាក់មនុស្សហើយសម្លាប់ចោលមានទេ នៅហ្នឹង?

មានៈ: ទេ!មិនដែលឮគេនិយាយទេ ទឹមឮសព្វថ្ងៃនេះឮគេនិយាយថាគេមានគុកដាក់ឲ្យមនុស្សនៅ ។ មិនដែលឮទេ មិនដែលដឹងទេ ។

វណ្ណៈ: អីចឹងដល់ពេលក្រោយ៧៩ មានគេគាស់សាកសពកន្លែងណាយកទៅតំកល់ដីម្បីគោរព ដើម្បីអីទេ មានគេគាស់សាកសពដាក់វត្តដាក់អី?

មានៈ: ខ្ញុំមិនដែលមមានទេ តែកន្លែងខ្ញុំនោះអត់ ខ្ញុំនៅតែចល័តរហូតលោកគ្រូ ។ ខ្ញុំមិនដឹងទេ ទាល់តែសួរគាត់តាមភូមិបានគាត់ដឹង ។

វណ្ណៈ: បាទ!ចុះកាលជំនាន់ខ្មែរក្រហម មីងបានរៀបការទេ?

មានៈ: អត់ទេ! ខ្ញុំទឹមបានយួនចូលនេះហើយ ៨០គត់នេះ ចប់ហើយក៏បានប្ដីអាយុ២៣ ។

វណ្ណៈ: បាទ!អីចឹងពេលយួន ចូលមកហើយបានមីងត្រឡប់មកផ្ទះ ម៉ោស្រុកកំណើតទៅ ។

មានៈ: ចាំ!មកស្រុកកំណើត ។

វណ្ណៈ: ហើយឆ្នាំណាមីងបានរៀបការ?

មានៈ: ខ្ញុំមកនេះខ្ញុំអាយុ២៣ មិនដឹងឆ្នាំណា ។ ៨៨ ដែលចប់ប៉ុន្មាន?

វណ្ណៈ: ចប់៧៩ យួនចូល?

មានៈ: ចាំ!ហ្នឹងឯង ខ្ញុំមកដល់ប៉ុន្មានថ្ងៃក៏ ប្រហែលយើងបាន១០ថ្ងៃមិនដឹង បានម៉ែឲ្យបានប្ដី អាយុ២៣ហើយដែលខ្ញុំបានប្ដី មកដល់ឥឡូវខ្ញុំអាយុ៥៣ហើយ ប៉ុន្មានឆ្នាំហើយ ប្រហែល៣០-២០ឆ្នាំហើយ ។

វណ្ណៈ បាទ!អ៊ីចឹងមីងខបមាថាក្រោយមក មីងប្រកបមុខរបបធ្វើស្រែចំការធម្មតា ?

មានៈ ចាំ!ដល់នេះទៅគេចែករបប គេចែកក្នុងមាំគ្រួសារ អ្នកណាគ្រួសារច្រើនទៅ គេចែកមាំហិចតាកន្លះ ខ្ញុំធ្វើតែស្រែធ្វើតែចំការ គ្មានទៅណាទេ ។ មានតែដើររកស៊ីតាមនេះតិចតួច កាលនោះយើងអ៊ីវ៉ាន់វាថោក យើងរកបានបន្តិចបន្តួចទៅ ចេះតែបានហូប ។ ហើយសព្វថ្ងៃនេះបើមិនទៅរកពីបាងកកមិនបានស៊ីទេ រកវាមិនបានទេ ។

វណ្ណៈ អ៊ីចឹងមានន័យថា អ្នកស្រុកអ្នកភូមិទៅរកស៊ីនៅបាងកក ច្រើនគ្នាទៅស៊ីឈ្នួលគេហ្នឹង?

មានៈ ចាំ! ធ្វើការកសាងទៅ ខ្លះក៏រកង៉ាន់(ភាសាថៃ)ទៅ ខ្លះក៏កសាងទៅ អាខ្លះកន្លែងត្រង់ណាក៏គ្នាធ្វើយ៉ាប់ កន្លែងត្រង់ណាទៅក៏ធ្វើបានប្រាក់ទៅ កន្លែងណាក៏អត់ទៅ២-៣ខែបានគេបើកឲ្យម្ដងក៏មាន ប៉ុនកន្លែងកូនខ្ញុំសព្វថ្ងៃមិនអីទេ ស្រួលហើយ ប៉ុនគ្រាន់តែគ្នាប្រាក់វាតិច ។ វាថ្ងៃអង្ករក៏ថ្លៃ ម្ហូបក៏ថ្លៃដូចតែយើងសព្វថ្ងៃនេះអ៊ីចឹង ។

វណ្ណៈ អ៊ីចឹងកូនមីងប៉ុន្មានខែ ឬប៉ុន្មានឆ្នាំអីបានមកលេងម្ដង ឬយ៉ាំងម៉េច?

មានៈ ចាំ!១ឆ្នាំបានមកម្ដង ប៉ុនម្ដងនោះឯងខ្ញុំមិនសូវដែលបានទេ បានក្នុងមួយខែជួនណាក៏បីពាន់ទៅ ថ្ងៃណាទៅក៏ប្រាំពាន់ទៅ ប៉ុនខ្ញុំស៊ីខ្ញុំលេបថ្នាំហ្នឹងល្មមៗ មិនដែលបានទុកដាក់អីឲ្យកូនទេ ។

វណ្ណៈ អ៊ីចឹងផ្ញើរមករាល់ខែដែរ?

មានៈ ចាំ!រាល់ខែ ។

វណ្ណៈ បានកូនទៅប៉ុន្មាននាក់?

មានៈ តែម្នាក់ហ្នឹងឯងដែលទៅ ប្រុសម្នាក់នឹងដែលទៅ ខ្ញុំនៅជាមួយខ្ញុំហ្នឹង ខ្ញុំឈឺ ស្រីម្នាក់ដែលគេបានប្ដីបែកផ្ទះ គេទៅផ្សេងនោះក៏គេឲ្យខ្ញុំមួយខែណាក៏មួយពាន់ ជួនណាក៏ពីរពាន់គេឲ្យខ្ញុំលេបថ្នាំផ្សេង មួយពាន់ផ្សេង ក្នុងមួយខែវាអស់ហើយមួយពាន់ហ្នឹង គេឲ្យមួយពាន់ផ្សេងខ្ញុំលេបថ្នាំ ហើយគេឲ្យកូនគេ ដែលខ្ញុំមើលចៅ៣នាក់នេះ គេឲ្យក្នុងមួយខែគេឲ្យមួយពាន់ មីមួយនោះថ្ងៃណាគេបានទៅគេឲ្យមួយពាន់ ជួនណាគេឲ្យមួយពាន់ប្រាំរយ ខ្ញុំមើលចៅ៣នាក់កូនមីទី១ ទី២ ។ សព្វថ្ងៃនេះខ្ញុំបានរស់នឹងកូនទេ ហើយនឹងប្ដី ប្ដីគាត់ធ្វើផ្ទះក្នុងមួយថ្ងៃក៏បានមួយរយម្ភៃ បានអាហ្នឹងហើយក៏ជួយផង ចៅរៀន៣នាក់ទាំងអស់ ខ្ញុំសព្វថ្ងៃមិនទៅណារួចទេ នៅតែដេកដឹកតែថ្នាំ លេបតែថ្នាំ ។

វណ្ណៈ ខ្ញុំដូចជាអស់សំនួរសួរមីងហើយ ខ្ញុំចង់សួរទាក់ទងទៅរឿងសព្វថ្ងៃនេះ ដូចថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបានធ្វើការរំលោភសិទ្ធិមនុស្ស និយាយទៅធ្វើឲ្យប្រជាជនស្លាប់ជាង១លាននាក់ នៅក្នុងសម័យកាលគាត់ដឹកនាំមីង ដូចជាតាប៉ុល ពត

គាត់ស្លាប់ហើយ សព្វថ្ងៃហ្នឹងនៅតាអៀង សារី តានួន ជា ប្រពន្ធអៀង សារី ឈ្មោះអៀង ធីរិទ្ធិ តាខៀវ សំផន ហើយឌុចគេកាត់ទោសគាត់ហើយ អីចឹងនៅ៤នាក់ទៀតឆ្នាំនេះក៏គេកាត់ទោសអ្នកទាំង ៤នាក់នេះបន្តទៀតដែរ ។ តើមីងរាល់ថ្ងៃមានដឹងរឿងតុលាការឬក៏យ៉ាងម៉េចដែរ?

មានៈ មិនដឹង ខ្ញុំមិនដែលបានមើលទូរទស្សន៍ ។ ទាល់តែគាត់បានមើលពត៌មានបានគាត់ដឹង ប៉ុន្តែខ្ញុំមិន សូវដែលបានមើលផង រោគខ្ញុំគេឲ្យត្រូវការដេកឲ្យច្រើន ឲ្យហូបបាយហើយដេក យប់ឡើង ក៏ឲ្យដេក មិនសូវឲ្យទូរទស្សន៍ មិនសូវឲ្យនេះទេ បើថាមើលដឹងតែយ៉ាប់ហើយ ។

វណ្ណៈ ចុះមីងគិតថា កាត់ទោសហ្នឹងជាការត្រឹមត្រូវឬយ៉ាងម៉េច?

មានៈ ខ្ញុំចេះថាទៅ ការកាត់ទោសហ្នឹងជាការត្រឹមត្រូវហើយ បើកាលហ្នឹងវាធ្វើបាបយើងឡើងចង់ ងាប់ចង់រស់ ។

វណ្ណៈ បាទ!អីចឹងមីងខ្ញុំអរគុណមីងច្រើនមីងណាស់ ។

មានៈ ចា៎!

វណ្ណៈ បាទ!

«ចប់»